*ខួបអនុស្សាវរីយ៍លើកទី២០នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃអាទិត្យ ទី២៣ ខែតុលា ឆ្នាំ២០១១*

## *អ្នករាយការណ៍ពិសេសមានប្រសាសន៍ថា អស់រយៈពេល២០ឆ្នាំកន្លងមកហើយ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅតែមាន អនុភាពសម្រាប់កម្ពុជា*

ហ្សឺណែវ៖ លោកសាស្ត្រាចារ្យ **សុរិយា ស៊ូប៊ីឌី** អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជាបានរំឭកឡើងវិញនូវខួបអនុស្សាវរីយ៍លើកទី២០នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលបានចាប់ផ្តើមដំណើរការនាំយកសន្តិភាពមកឲ្យកម្ពុជាបន្ទាប់ពីជម្លោះជាងពីរទសវត្សរ៍ថា "កាលពី២០ឆ្នាំកន្លងទៅ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានដាក់ចុះនូវទស្សនៈវិស័យច្បាស់លាស់សម្រាប់កម្ពុជាថ្មី ក្នុងការកសាងប្រទេសឡើងវិញដោយផ្អែកលើមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ" ។

លោក ស៊ូប៊ីឌីមានប្រសាសន៍ថា "អស់រយៈពេល២០ឆ្នាំកន្លងទៅនេះ ប្រទេសកម្ពុជាមានការរីកចំរើនដែលមិនអាចប្រកែកបាន ដោយសន្តិភាព និងស្ថេរភាពនាំមកនូវការរីកចំរើនដ៏ធំធេង ទាំងធនធាន និងការអភិវឌ្ឍន៍។ ស្ថាប័ននានាត្រូវបានបង្កើតឡើង ហើយច្បាប់ជាច្រើនត្រូវបានអនុម័ត។" "ទោះជាដូច្នោះក៏ដោយ ក៏ការប្រឈមនៅតែបន្តមាន ក្នុងការអនុវត្តន៍ភាគច្រើននៃច្បាប់ទាំងនេះ ក៏ដូចគ្នានឹងការប្រព្រឹត្តទៅដ៏មានប្រសិទ្ធិភាពនៃស្ថាប័នទាំងនេះ។"

អ្នករាយការណ៍ពិសេសបានជំរុញកម្ពុជា ក៏ដូចជាភាគីនានាដែលបានជួយដល់ប្រទេសនេះ ឲ្យឆ្លុះបញ្ចាំងឡើងវិញ ថាតើទស្សនៈវិស័យនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសត្រូវបានអនុវត្តយ៉ាងស្មោះស្ម័គ្រ ឬយ៉ាងណា។ កិច្ចព្រមព្រៀងនេះនឹងនៅតែមានតំលៃ រហូតដល់ទស្សនៈវិស័យទាំងឡាយដែលមានចែងក្នុងនោះក្លាយជា ការពិតសម្រាប់ពលរដ្ឋកម្ពុជាទាំងអស់។

នៅក្នុងស្មារតីនេះ ឯករាជភាពនៃប្រព័ន្ធតុលាការត្រូវការចាក់គ្រឹះលើច្បាប់ជាមូលដ្ឋាននានាស្តីពីតុលាការ ដែលបាននឹងកំពុងរង់ចាំ ការអនុម័តតាំងពីឆ្នាំ១៩៩៣មក។ លទ្ធិប្រជាធិបតេយ្យតាមបែបពហុបក្សនៅក្នុងប្រទេសត្រូវការធ្វើឲ្យស៊ីជំរៅ និងពង្រឹង ជាពិសេសខណៈដែលកម្ពុជាកាន់តែរំកិលជិតដល់ការបោះឆ្នោតជាតិ។

លោក ស៊ូប៊ីឌី កត់សំគាល់ថា "ដូចគ្នានោះផងដែរ គេត្រូវការដោះស្រាយបញ្ហានិទណ្ឌភាពចំពោះបទឧក្រិដ្ឋនៃរបបខ្មែរក្រហម ក៏ដូចជាបទឧក្រិដ្ឋនានាដែលត្រូវបានប្រព្រឹត្តជាបន្តបន្ទាប់ចាប់តាំងពីពេលនោះមក។ សិទ្ធិសេរីភាពនៃការបង្កើតសមាគម ដែលត្រូវបានចែងយ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀងនោះ ត្រូវការការពារ និងថៃទាំយ៉ាងយកចិត្តទុកដាក់ ដើម្បីឲ្យកម្ពុជានៅតែស្ថិតនៅលើវិថីដ៏ត្រឹមត្រូវ។ "

អ្នករាយការណ៍បិសេសគូសបញ្ជាក់ថាភាគីហត្ថលេខីជាច្រើននៅតែបន្តមានតួនាទី និងទំនួលខុសត្រូវដែលត្រូវបំពេញ ក្នុងការដោះស្រាយការប្រឈមទាំងនេះ និងសម្រេចឲ្យបាននូវទស្សនៈវិស័យនៃកិច្ចព្រមព្រៀងនេះ។ លោកពន្យល់ថា "អ្នកដើរតួនាទីដំបូងគេ និងសំខាន់បំផុតនោះគឺរដ្ឋាភិបាល។ រដ្ឋហត្ថលេខីទាំងដប់ប្រាំបី នៃកិច្ចព្រមព្រៀងនេះ ក៏បានចូលរួម លើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្សនៅកម្ពុជាផងដែរ។ អង្គការសហប្រជាជាតិ ដែលជាចំនុចកណ្តាលចំពោះក្របខណ្ឌនៃកិច្ចព្រមព្រៀងនេះ មានតួនាទីដ៏សំខាន់ ដែលត្រូវបំពេញ រួមបញ្ចូលទាំងការិយាល័យ OHCHR ប្រចាំកម្ពុជា និងអ្នករាយការណ៍ពិសេស ដែលសុទ្ធតែមានអាណត្តិ ចេញពីកិច្ចព្រមព្រៀងនេះមក។"

លោក ស៊ូបឺឌី ថ្លែងថា "ខណៈដែលយើងប្រារព្ធខួបអនុស្សាវរីយ៍លើកទី២០នៃកិច្ចព្រមព្រៀងនេះ គ្រប់ភាគីទាំងអស់គួរបញ្ជាក់ ឡើងវិញអំពីការប្តេជ្ញារបស់ខ្លួនក្នុងការអនុវត្តយ៉ាងពេញលេញតាមស្មារតីនៃកិច្ចព្រមព្រៀងនេះ ដើម្បីឲ្យទស្សនៈវិស័យ និងកេរ្តិ៍តំណែលនៃកិច្ចព្រមព្រៀងសន្តិភាពក្លាយជាការពិត។"

ចប់

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូបឺឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា កាលពីខែមិនា ឆ្នាំ២០០៩។ បច្ចុប្បន្ន លោកគឺជាសាស្ត្រាចារ្យនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។*

*គេហទំព័រការិយាល័យ OHCHR ប្រចាំកម្ពុជា*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*លិខិតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ៖ http://www2.ohchr.org/english/law/index.htm#core*
*សម្រាប់ព័ត៌មានបន្ថែម និង**សំណើរព័ត៌មាន** សូមទំនាក់ទំនងកញ្ញា Maureen Teo (Tel: + 41 22 928 9632 / email: mteo@ohchr.org).*

*សម្រាប់**សំណើរព័ត៌មាន** ទាក់ទងនឹងអ្នកជំនាញការឯករាជ្យ អ.ស.ប ផ្សេងៗទៀត សូមទំនាក់ទំនង៖* Xabier Celaya, OHCHR Media Unit (+ 41 22 917 9383 / xcelaya@ohchr.org)

**អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស សូមផ្សាភ្ជាប់ទំនងទំនងជាមួយយើងតាមរយៈ៖**
**Facebook:** https://www.facebook.com/unitednationshumanrights
**Twitter:** http://twitter.com/UNrightswire
**YouTube:** http://www.youtube.com/UNOHCHR